ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..........................................................

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១
# និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១០ របស់ធនាគារជាតិនៃកម្ពុជា

ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ នៅធនាគារជាតិនៃកម្ពុជា

សូមគោរព :

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា

ថ្ងៃនេះ ខ្ញុំមានក្ដីសោមនស្សរីករាយជាអតិបរមា ដោយបានមកជួបជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា ក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១០ របស់ធនាគារជាតិនៃកម្ពុជា ។ ជារៀងរាល់ឆ្នាំ យើងតែងរៀបចំសន្និបាតបូកសរុបលទ្ធផលការងារ ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយនិងអបអរសាទរពីលទ្ធផលការងារ ដែលធនាគារជាតិនៃកម្ពុជាបានសម្រេចកន្លងមក និងម៉្យាងទៀត ដើម្បីបង្កបរិយាកាសឲ្យមន្ត្រីបុគ្គលិករបស់យើង ទាំងនៅទីស្នាក់ការកណ្ដាលនិងនៅរាជធានី-ខេត្ត បានជួបប្រាស្រ័យទាក់ទងគ្នាជាបណ្ដាញការងារ និងរាប់អានគ្នាកាន់តែជិតស្និទ្ធ ដូចយើងរស់នៅក្រោមដំបូលគ្រួសារតែមួយ ។

អង្គសន្និបាតនេះ បានរៀបចំឡើងបន្ទាប់ពីយើងបានប្រារព្ធធ្វើពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣០ នៃការបោះផ្សាយប្រាក់រៀលដាក់ឲ្យចរាចរឡើងវិញ កាលពីដើមឆ្នាំកន្លងទៅនេះ ។ ពិធីនេះ មានសារៈសំខាន់ណាស់សម្រាប់ប្រជាជននិងប្រទេសកម្ពុជា ដែលបានឆ្លុះបញ្ចាំងឲ្យឃើញពីការកសាងអត្តសញ្ញាណជាតិ អធិបតេយ្យ និងអំណាចខាងផ្នែកសេដ្ឋកិច្ចរបស់រដ្ឋ និងតួនាទីប្រាក់រៀលក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមក្នុងរយៈពេល ៣០ឆ្នាំកន្លងមកនេះ ។


ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្ដៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលជាតំណាងមកពីនាយកដ្ឋាននានានៅទីស្នាក់ការកណ្ដាល និងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត បានអញ្ជើញចូលរួមក្នុងអង្គសន្និបាតរបស់យើងនាពេលនេះ។ ទន្ទឹមពេលនេះ ខ្ញុំសូមថ្លែងអំណរគុណនិងកោតសរសើរយ៉ាងខ្លាំង ចំពោះស្មារតីទទួលខុសត្រូវក្នុងការងារ និងកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីបុគ្គលិកយើង ដែលបានរួមសាមគ្គីគ្នាជាប្រពៃណីដើម្បីកសាងសមិទ្ធផលជូនធនាគារជាតិនៃកម្ពុជាកន្លងមក ពោលគឺបានរួមចំណែកកសាងប្រព័ន្ធធនាគារឲ្យមានសុវត្ថិភាព និងបានទទួលការជឿទុកចិត្តពីសាធារណជន ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ខ្ញុំឆ្លៀតឱកាសនេះសូមជម្រាបថា សន្និបាតរបស់យើងថ្ងៃនេះរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយពីលទ្ធផលការងារក្នុងឆមាសទី១ នៅឆ្នាំ២០១០ ដូចតទៅ៖

## I/- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០១០

នៅឆមាសទី១ ឆ្នាំ២០១០ នេះ កំណើនសេដ្ឋកិច្ចពិភពលោកបានរើបឡើងវិញដោយសារភាពខ្លាំងនៃមូលដ្ឋានគ្រឹះសេដ្ឋកិច្ចអាស៊ីជាអ្នកនាំមុខ ក្នុងនោះប្រទេសចិន ឥណ្ឌា និងឥណ្ឌូណេស៊ីបានដើរតួសំខាន់ជាងគេ ។ សេដ្ឋកិច្ចអាស៊ីនៅសតវត្សរ៍ទី២១ នេះ ត្រូវបានគេចាត់ទុកថា ជាក្បាលម៉ាស៊ីនថ្មីទី២ សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចពិភពលោកនៅពេលអនាគត ។ ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោកដែលដឹកមុខដោយអាស៊ីនេះ នៅមានភាពផុយស្រួយនៅឡើយ ។

តាមការព្យាករដោយប្រុងប្រយ័ត្នរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅឆ្នាំ២០១០ នេះ សេដ្ឋកិច្ចពិភពលោកអាចមានកំណើន ៤,៥% ក្នុងនោះប្រទេសកំពុងអភិវឌ្ឍន៍មានកំណើន ៦,៣% និងប្រទេសអភិវឌ្ឍន៍ ២,៣% ។ សេដ្ឋកិច្ចសហរដ្ឋអាមេរិកអាចកើន ៣,១% និងសហគមន៍អឺរ៉ុបកើន ១% ខណៈដែលប្រទេសចិននឹងកើន ១០% ឥណ្ឌា ៨,៨% ឥណ្ឌូណេស៊ី ៥,៥% អាស៊ានធំ ៥ កើន ៥,៤% និងសេដ្ឋកិច្ចប្រទេសអាស៊ានទាំង១០ កើន ៥,១% ។

នៅឆ្នាំ២០១០ សេដ្ឋកិច្ចកម្ពុជានឹងមានកំណើនក្នុងកម្រិត ៥% ធៀបនឹងឆ្នាំ២០០៩ ត្រឹម ០,១% ។ កំណើននេះកើនឡើងដោយសារការរើបឡើងវិញនៃវិស័យវិនិយោគ សំណង់

ទេសចរណ៍ កសិកម្ម និងឧស្សាហកម្មវាយនភណ្ឌ បន្ទាប់ពីរាជរដ្ឋាភិបាលបានពង្រឹងការអនុវត្តវិធានការជាកញ្ចប់ និងនយោបាយទ្រទ្រង់មួយចំនួនទៀតប្រកបដោយប្រសិទ្ធភាពក្នុងការរក្សាស្ថិរភាពស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

**II/- លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០១០ កន្លងមក**

នៅឆមាសទី១ ឆ្នាំ២០១០ នេះ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជា បានខិតខំបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន សំដៅរួមចំណែកពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព និងទទួលបានលទ្ធផលដូចខាងក្រោម ៖

ជារួម ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅតែរក្សាភាពល្អប្រសើរនៃកំណើនជាប់ជាប្រចាំ ទោះបីជាអត្រាអតិផរណាបានកើនឡើងបន្តិចក៏ដោយ ក៏តម្លៃប្រាក់រៀលមានស្ថិរភាពល្អប្រសើរ ។ អត្រាប្តូរប្រាក់រៀលចុះថ្លៃប្រមាណ ២% ក្នុងឆមាសទី១ ឆ្នាំ២០១០ ធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០៩ ។ ស្ថិរភាពនៃតម្លៃប្រាក់រៀលបានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនចំពោះសេដ្ឋកិច្ចកម្ពុជា ។ ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ យើងអនុវត្តដោយឈរលើមូលដ្ឋានប្រុងប្រយ័ត្ន គឺសុវត្ថិភាពនិងសាច់ប្រាក់ងាយស្រួលជាចម្បង ។ គិតមកត្រឹមឆមាសទី១ឆ្នាំនេះ ទុនបម្រុងអន្តរជាតិវិនិយោគបានកើនដល់ ២,៩៣ពាន់លានដុល្លារ ធៀបនឹងគ្រាដូចគ្នានៅឆ្នាំ២០០៩ ដែលមានត្រឹម ២,៤៥ ពាន់លានដុល្លារអាមេរិក ដែលអាចធានាការនាំចូលបាន ៤ខែ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ របស់រាជរដ្ឋាភិបាល ហើយទទួលបានលទ្ធផលល្អប្រសើរដូចខាងក្រោម ៖

**១/-វិស័យធនាគារ** : មានការរីកចម្រើនទាំងវិសាលភាពនិងទំហំប្រតិបត្តិការ មានជំនឿទុកចិត្តពីសាធារណជន និងបានដើរតួនាទីស្នូលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ នៅឆមាសទី១ ឆ្នាំនេះ ផ្នែកវិសាលភាព ធនាគារពាណិជ្ជកើនដល់ចំនួន ២៧ ធនាគារឯកទេសចំនួន ៦ ដោយសារមានវិនិយោគិនអាមេរិក កូរ៉េ ម៉ាឡេស៊ី ឥណ្ឌា និងវៀតណាម នាពេលថ្មីៗនេះ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ២១ ។ ថ្មីៗនេះ ការិយាល័យតំណាងធនាគារ

កសិកម្មនិងអភិវឌ្ឍន៍ជនបទនៃវៀតណាម បានប្រែក្លាយជាធនាគារពាណិជ្ជ ។ ប្រការនេះបង្ហាញអំពីកំណើនជំនឿទុកចិត្តរបស់វិនិយោគិនបរទេស មកលើប្រព័ន្ធធនាគារនៅកម្ពុជាបន្ថែមទៀត ។ ចំណែកឯទំហំប្រតិបត្តិការវិញ ទ្រព្យសកម្មសរុបកើនឡើង ៩,៤% ប្រាក់បញ្ញើកើនឡើង ១៥% និងឥណទានសរុបរបស់ប្រព័ន្ធធនាគារកើនឡើង ៩,៨% ធៀបនឹងខែធ្នូឆ្នាំ២០០៩ ។ ការវិវត្តរីកចម្រើននេះគួបផ្សំនឹងការអនុវត្តវិធានការប្រុងប្រយ័ត្ន បានធ្វើឲ្យឥណទានមិនដំណើរការ (NPL) ថយចុះជាលំដាប់មកត្រឹម ៤,៦% នៃកញ្ចប់ឥណទានសរុបនៅខែមិថុនា ឆ្នាំ២០១០ ។

**២/- ការងារត្រួតពិនិត្យធនាគារ** : ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ និងបានសហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដើម្បីចុះទៅត្រួតពិនិត្យដល់ទីកន្លែង និងត្រួតពិនិត្យលើឯកសារ សំដៅជួយពង្រឹងអភិបាលកិច្ចល្អនិងភាពរឹងមាំរបស់គ្រឹះស្ថានធនាគារ ។ ក្នុងរយៈពេល ៦ខែនេះ យើងបានបញ្ចប់ការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារចំនួន ១២ ឃើញថាស្ថានភាពហិរញ្ញវត្ថុល្អប្រសើរ និងគោរពតាមវិធានការប្រុងប្រយ័ត្ន ។ ប៉ុន្តែមានធនាគារមួយចំនួនទៀតនៅមានចំណុចខ្វះខាត ដែលចំណុចខ្វះខាតទាំងនេះ យើងបានផ្តល់អនុសាសន៍ដើម្បីកែតម្រូវ និងមានវិធានការដោះស្រាយតាមស្ថានភាពជាក់ស្តែង ។

**៣/- វិស័យមីក្រូហិរញ្ញវត្ថុ** : ជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។ វិស័យនេះមានការរីកចម្រើនយ៉ាងខ្លាំង និងមានហេដ្ឋារចនាសម្ព័ន្ធរឹងមាំដល់ជនបទ ។ ឥណទានផ្តល់ដោយវិស័យមីក្រូហិរញ្ញវត្ថុ មានការកើនឡើងគួរឲ្យកត់សម្គាល់ ហើយបានរួមចំណែកអភិវឌ្ឍអាជីវកម្មធុនតូចនិងមធ្យម និងវិស័យកសិកម្មនៅកម្ពុជា ។ ភាពជឿនលឿននេះបញ្ជាក់ឲ្យឃើញថា ប្រជាពលរដ្ឋកម្ពុជាកាន់តែមានការយល់ដឹងពីសារៈសំខាន់នៃសេវាមីក្រូហិរញ្ញវត្ថុ និងវប្បធម៌ឥណទានកាន់តែប្រសើរឡើង ។

**៤/- ការពង្រឹងក្របខ័ណ្ឌច្បាប់** : បន្ទាប់ពីច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុត្រូវបានអនុម័តកាលពីឆ្នាំ២០០៩ សម្រាប់ធ្វើជាមូលដ្ឋានគតិយុត្តិក្នុងការកៀងគរប្រភពទុនរយៈពេលវែងទៅអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម (SME) នៅកម្ពុជា រួចមក យើងបានបន្តការកែលម្អវិធានការប្រុងប្រយ័ត្ន និងរៀបចំបទបញ្ញាមួយចំនួន ដើម្បីឲ្យការអនុវត្តប្រព្រឹត្តទៅដោយរលូននិងស្របតាមស្ថានភាពទីផ្សារ ។

**៥/- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា** ៖ ក្នុងឆមាសទី១ នេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចុះទៅត្រួតពិនិត្យយន្តការអនុវត្តច្បាប់ របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យមើលប្រតិបត្តិការសង្ស័យ និងរបាយការណ៍លំហូរសាច់ប្រាក់សង្ស័យ។ ជាលទ្ធផល អង្គភាពក៏បានត្រួតពិនិត្យធនាគារចំនួន៨ និងបានទទួលរបាយការណ៍សង្ស័យពីធនាគារចំនួន៤ មានជាប់ពាក់ព័ន្ធនឹងសកម្មភាពហិរញ្ញប្បទានភេរវកម្ម និងការក្លែងបន្លំផ្ទេរប្រាក់ ។

អង្គភាពនេះ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសមួយចំនួន ដូចជា ម៉ាឡេស៊ី នេប៉ាល់ ស្រីលង្កា និងកំពុងត្រៀមចុះហត្ថលេខាជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុវៀតណាម មជ្ឈមណ្ឌលស៊ើបការណ៍ហិរញ្ញវត្ថុប្រទេសជប៉ុន ការិយាល័យត្រួតពិនិត្យហិរញ្ញវត្ថុសហព័ន្ធរុស្ស៊ី និងការិយាល័យប្រឆាំងការសម្អាតប្រាក់ក្រុងតៃប៉ិ ដើម្បីសហការជាមួយសហគមន៍ជាតិ-អន្តរជាតិ ការពារទប់ស្កាត់ និងប្រឆាំងរាល់បទល្មើសទាក់ទងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ក្រៅពីនេះ យើងក៏បានសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ក្នុងការប្រមូលព័ត៌មានចាំបាច់មួយចំនួន ដើម្បីរាយការណ៍ជូនមហាសន្និបាតប្រចាំឆ្នាំ២០១០ របស់ក្រុមប្រទេសប្រឆាំងការសម្អាតប្រាក់នៅតំបន់អាស៊ីប៉ាស៊ីហ្វិក (APG) នៅប្រទេសសិង្ហបុរី កាលពីដើម ខែកក្កដា ឆ្នាំ២០១០ កន្លងមកនេះ ។

**៦/- ការពង្រឹងអភិបាលកិច្ចល្អ** ៖ នៅឆមាសទី១ ឆ្នាំ២០១០ នេះ មន្ត្រីជំនាញយើងបានចុះធ្វើសវនកម្មនៅខុទ្ទកាល័យធនាគារជាតិនៃកម្ពុជា និងសាខាធនាគារជាតិនៃកម្ពុជាចំនួន ៥ គឺ ខេត្តកណ្ដាល ខេត្តព្រះសីហនុ ខេត្តរតនគីរី ខេត្តកំពង់ចាម និងខេត្តសៀមរាប ។ ចំពោះការងារអធិការកិច្ចវិញ យើងបានចុះឆ្មក់ត្រួតពិនិត្យដោយមិនជូនដំណឹងមុនបានចំនួន ៩ លើក ទៅលើការងារគ្រប់គ្រងសុវត្ថិភាពសាច់ប្រាក់ និងលំហូរការងារជាប់ជាប្រចាំនៅទីស្នាក់ការកណ្ដាលនិងសាខារាជធានី-ខេត្ត ។ ជាលទ្ធផល យើងពិនិត្យឃើញថាប្រតិបត្តិការធនាគារជាតិនៃកម្ពុជាបានប្រព្រឹត្តទៅដោយរលូន និងមានលក្ខណៈល្អប្រសើរ ។

**៧/- ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត** ៖ យើងកំពុងបានបន្តពង្រឹងប្រតិបត្តិការរបស់ខ្លួន ទាំងនៅទីស្នាក់ការកណ្ដាលនិងសាខាខេត្ត ដើម្បីចូលរួមអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលដំណាក់កាលទី២ ឲ្យកាន់តែមានប្រសិទ្ធភាព ។ យើងបានរៀបចំកែលម្អការិយាល័យធ្វើការនៅសាខាធនាគារជាតិនៃកម្ពុជាតាមខេត្តមួយចំនួន ដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងគណនីរដ្ឋ និងធ្វើឲ្យកាន់តែរលូនចំពោះការបើកប្រាក់បៀវត្សជូនអង្គភាពរដ្ឋជុំវិញខេត្ត និងទទួលបានការបង់ពន្ធគ្រប់ប្រភេទ។

យើងបានដាក់ឲ្យអនុវត្តកម្មវិធីប្រព័ន្ធធនាគារស្នូល (CBS) ក្នុងគោលបំណងដើម្បី *១)-* ពង្រឹងតម្លាភាពនិងជួយសម្រួលប្រតិបត្តិការគ្រប់គ្រងលំហូរការងារ រវាងនាយកដ្ឋានអាទិភាព ៤ គឺ នាយកដ្ឋានប្រតិបត្តិការ បោះផ្សាយនិងឃ្លាំងបេឡា គ្រប់គ្រងការប្តូរប្រាក់ និងនាយកដ្ឋានគណនេយ្យ *២)-* ពន្លឿនប្រតិបត្តិការបើក-ដាក់ប្រាក់ ការបង់ពន្ធ និងការផ្ទេររវាងគណនី និង *៣)-* ដើម្បីឲ្យនាយកដ្ឋានទាំង៤ ទទួលបានទិន្នន័យក្នុងពេលដំណាលគ្នា (Real time) ចំពោះប្រតិបត្តិការតែមួយ ។ យើងបានដាក់ឲ្យអនុវត្តប្រព័ន្ធធនាគារស្នូល និងបណ្តុះបណ្តាលមន្ត្រីជំនាញនៃនាយកដ្ឋានជំនាញទាំង៤ ។ យើងបានដំឡើងប្រព័ន្ធធនាគារស្នូលនៅសាខាខេត្តមួយចំនួនទៀត ព្រមទាំងបានបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីអនុវត្តភារកិច្ចនេះឲ្យប្រព្រឹត្តទៅដោយរលូនផងដែរ ។

៨/- **ការអភិវឌ្ឍទីផ្សារអន្តរធនាគារ** : ដើម្បីអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារ និងទីផ្សារមូលបត្រនៅកម្ពុជា ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាកំពុងពិចារណារៀបចំក្រុមខ័ណ្ឌច្បាប់ ដើម្បីធ្វើមូលបត្រនីយកម្មប្រាក់បញ្ញើមានកាលកំណត់របស់បណ្តាធនាគារនៅធនាគារជាតិនៃកម្ពុជា ។

៩/- **ការឈប់គ្រប់គ្រងអាជីវកម្មលក់ដូរគ្រឿងអលង្ការធ្វើពីលោហធាតុ និងត្បូងថ្មមានតម្លៃ** : យើងសម្រេចផ្ទេរប្រភេទអាជីវកម្មគ្រឿងអលង្ការ ឲ្យស្ថិតនៅក្រោមសមត្ថកិច្ចក្រសួងពាណិជ្ជកម្ម និងបានពង្រឹងការគ្រប់គ្រងតែសកម្មភាពធ្វើអាជីវកម្មលោហធាតុ និងត្បូងថ្មមានតម្លៃ ដែលចាត់ទុកជាវូបិយប័ណ្ណវិញ ទាំងនៅរាជធានីនិងខេត្តនានា ។

**១០/- សមាគមមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា** បានជួយរួមចំណែកដោះស្រាយការលំបាករបស់មន្ត្រីបុគ្គលិករបស់យើង ។ ជាក់ស្តែង ទំហំនៃការលំបាករបស់មន្ត្រីបុគ្គលិកយើងមានលក្ខណៈខុសគ្នាពីម្នាក់ទៅម្នាក់ ពីមួយករណីទៅមួយករណី ដូច្នេះ សមាគមត្រូវពិនិត្យលទ្ធភាពជាក់ស្តែងបន្ថែមទៀត ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

**១១/- ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិវិញ** : នៅឆមាសទី១ ឆ្នាំ២០១០ ធនាគារជាតិនៃកម្ពុជា មានកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាល និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិផ្សេងៗ ដូចជា ៖

**មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)** : ក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក បានមកបំពេញបេសកកម្មនៅកម្ពុជា នៅខែមីនា ឆ្នាំ២០១០ ដើម្បីអនុវត្តកម្មវិធីវាយតម្លៃវិស័យហិរញ្ញវត្ថុ (FSAP) និងបានកោតសរសើរធនាគារជាតិនៃកម្ពុជាថា បានចាត់វិធានការទាន់ពេល ក្នុងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ការបង្កើតឧបករណ៍ឥណទានវិបារូបន៍ (OD) ការពង្រឹងប្រព័ន្ធចំណាត់ថ្នាក់ឥណទាន និងប្រព័ន្ធទុនបម្រុងកាតព្វកិច្ចបានល្អប្រសើរ ។ IMF បានបន្តផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ដើម្បីតាមដានស្ថិរភាពហិរញ្ញវត្ថុ និងពង្រឹងប្រសិទ្ធភាពការត្រួតពិនិត្យធនាគារថែមទៀត។

**ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)** : ធនាគារជាតិនៃកម្ពុជាបានដើរតួនាទីស្នូល ក្នុងការអនុវត្តគម្រោងការងារនៅក្នុងអនុកម្មវិធីទី៤ ដោយរលូនស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយបច្ចេកទេសដើម្បីរៀបចំប្រព័ន្ធជាតិនិងទូទាត់សងប្រាក់ ធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ឲ្យទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ និងរៀបចំសំណុំកម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទី៣ បន្តទៀត ។

**ក្រុមប្រទេសអាស៊ាន (ASEAN)** : ប្រតិភូធនាគារជាតិនៃកម្ពុជាបានចូលរួមជាប្រចាំក្នុងកិច្ចប្រជុំថ្នាក់នយោបាយ និងបច្ចេកទេសសំខាន់ៗរបស់អាស៊ាននិងអាស៊ានបូកបី ក្នុងកិច្ចសហប្រតិបត្តិការតាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងតំបន់ អនុវត្តផែនទីមគ្គុទ្ទេសក៍នៃសមាហរណកម្មរូបិយវត្ថុ-ហិរញ្ញវត្ថុអាស៊ាន ពង្រឹងទីផ្សារសញ្ញាបណ្ណក្នុងតំបន់ និងអនុវត្តយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ាន ។

**មជ្ឈមណ្ឌល SEACEN** : យើងបានទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ (SEACEN) លើកទី៤៥ និងកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាល SEACEN លើកទី២៩ កាលពីថ្ងៃទី២៦-២៧ ខែកុម្ភៈ ឆ្នាំ២០១០ នៅខេត្តសៀមរាប និងបានសហការជាមួយមជ្ឈមណ្ឌល SEACEN រៀបចំសិក្ខាសាលានៅខេត្តសៀមរាប និងបានបញ្ជូនមន្ត្រីជំនាញទៅចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានានៅក្រៅប្រទេស ដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នា ។

**កិច្ចប្រជុំធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone)** : គណៈប្រតិភូធនាគារជាតិនៃកម្ពុជាបានទៅចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ២០១០ លើកទី១៧ របស់ធនាគារ

កណ្ដាលនៃក្រុមប្រទេសនិយាយភាសាបារាំង នៅទីក្រុងម៉ុងត្រេអាល ប្រទេសកាណាដា ។ តាមគម្រោងប្តូរវេន ធនាគារជាតិនៃកម្ពុជាមានកិត្តិយសធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំលើកទី១៨ របស់ធនាគារកណ្ដាលនៃក្រុមប្រទេសនិយាយភាសាបារាំង នៅខែមិថុនា ឆ្នាំ២០១១ ខាងមុខនេះ នៅខេត្តសៀមរាប។

**កិច្ចសហប្រតិបត្តិការទ្វេភាគី** : យើងបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្ដាលថៃ កូរ៉េ បារាំង វៀតណាម ឡាវ ម៉ាឡេស៊ី លុចហ្សំបួរ អាល្លឺម៉ង់ និងធនាគារកណ្ដាលនៃបណ្ដាប្រទេសអាស៊ានមួយចំនួនទៀត ។ យើងនឹងរៀបចំកិច្ចប្រជុំទ្វេភាគីជាមួយធនាគារកណ្ដាលថៃ នៅខេត្តសៀមរាប នៅចុងខែកក្កដានេះ និងចូលរួមកិច្ចប្រជុំទ្វេភាគីជាមួយធនាគារកណ្ដាលម៉ាឡេស៊ី នៅដើមខែសីហាខាងមុខនេះ ។

តាមរយៈកិច្ចសហប្រតិបត្តិការនេះ យើងតែងតែបានទទួលជំនួយបច្ចេកទេស អាហារូបករណ៍ថ្នាក់អនុបណ្ឌិត និងការបណ្ដុះបណ្ដាលរយៈពេលខ្លី ដល់មន្ត្រីធនាគារជាតិនៃកម្ពុជា ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

សរុបមក សមិទ្ធផលទាំងឡាយដែលយើងមានសព្វថ្ងៃនេះ គឺកើតចេញពីការខិតខំប្រឹងប្រែងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងការប្រើប្រាស់កម្លាំងសរុបរបស់មន្ត្រីបុគ្គលិកយើងទាំងអស់គ្នា ។ ដើម្បីជ្រាបពីសមិទ្ធផលលម្អិតផ្សេងទៀត សូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្ដាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ និងការខិតខំប្រឹងប្រែងរបស់សមាជិកក្រុមប្រឹក្សាភិបាលនិងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានរួមចំណែកកសាងធនាគារជាតិនៃកម្ពុជា ឲ្យទទួលបានលទ្ធផលល្អប្រសើរគួរជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៅទៀត ។ អង្គសន្និបាតរបស់យើងនឹងប្រព្រឹត្តទៅរយៈពេលមួយថ្ងៃ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ខិតខំស្ដាប់របាយការណ៍ស្ដីពីលទ្ធផលការងារដែលអនុវត្តកន្លងមក និងអនុសាសន៍ផ្សេងៗ ដើម្បីយកទៅអនុវត្តការងាររបស់ខ្លួនឲ្យបានជោគជ័យ និងមានប្រសិទ្ធភាព ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនឹងនេះ សូមឲ្យអង្គសន្និបាតរបស់យើងថ្ងៃនេះ មានដំណើរការប្រកបដោយជោគជ័យ ។

ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**!